Washington State Department of Health

Washington Breast & Cervical Health Program
Take Charge of Your Health!

**July 2007 – June 2008**

# ព័ត៌មានស្តីពីកម្មវិធីថែទាំសុខភាពសុដន់ និងស្បូននៃរដ្ឋវ៉ាស៊ីនតោន

**កម្មវិធីថែទាំសុខភាពសុដន់ និងស្បូននៃរដ្ឋវ៉ាស៊ីនតោន (Washington Breast and Cevical Health Program – WBCHP)** គឺជាកិច្ចប្រឹងប្រែងរួមគ្នាមួយរវាងបណ្តាពួកអាជីវករផ្តល់ការបម្រើផ្នែកសុខភាព, ក្រសួងសុខាភិបាលនៃរដ្ឋវ៉ាស៊ីនតោន (Washington State Department of Health – DOH), និង មជ្ឈមណ្ឌលគ្រប់គ្រងនិងការពារជម្ងឺរាតត្បាតរបស់សហរដ្ឋអាមេរិក (U.S. Centers for Disease Control and Prevention – CDC) ។ កម្មវិធីនេះផ្តល់ការឧបត្ថម្ភដល់ការពិនិត្យរុករកជម្ងឺមហារីកសុដន់ និងស្បូនជាប្រក្រតី ដើម្បីរកមើលការបង្កនៃជម្ងឺនេះក្នុងដំណាក់កាលបំបូងៗបង្អស់របស់វា ប្រយោជន៍ឲ្យគេអាចព្យាបាល ឬបន្សះវាឲ្យទាន់ពេល ។ ការចូលរួមក្នុងកម្មវិធីនេះគឺជាការស្ម័គ្រចិត្ត ។ អ្នកអាចដកខ្លួនចេញពីកម្មវិធី WBCHP ហើយលុបចោលសេចក្តីយល់ព្រមរបស់អ្នកក្នុងការអនុញ្ញាតឲ្យគេបញ្ចេញព័ត៌មាននានានៅពេលណាក៏បាន ។

អ្នកមានលក្ខណសម្បត្តិសម្រាប់ចូលរួមក្នុងកម្មវិធីនេះបាន ប្រសិនបើ ៖

- ✓ អ្នកមានអាយុពី 40 ទៅដល់ 64 ឆ្នាំ, និង
- ✓ ប្រាក់ចំណូលរបស់អ្នកនៅត្រឹម ឬស្ថិតក្រោមកម្រិត 250% នៃបន្ទាត់ក្រីក្ររបស់សហព័ន្ធ;
- ✓ អ្នកមិនទទួលជំនួយ Medicaid ឬ Medicare; ឬអ្នកមិនមានការធានារ៉ាប់រងឯកជន (លើកលែងតែក្នុងករណីដែលកិច្ចគាំពារនៃការធានារ៉ាប់រងរបស់អ្នកតម្រូវឲ្យអ្នកចេញប្រាក់បដិភាគច្រើនពេក (large deductible) ។

កម្មវិធី WBCHP ចេញប្រាក់សម្រាប់ថ្លៃពិនិត្យរុករកនានាជាប្រក្រតីចំពោះបណ្តាស្ត្រីចាប់ពីអាយុ 40 រហូតដល់ 64 ឆ្នាំ ។ ការពិនិត្យរុករកនេះរួមមាន ៖

- ✓ ការពិនិត្យមើលសុដន់ និងការថតឆ្លុះមើលសុដន់ដោយប្រើកាំរស្មីអ៊ិក្ស ហៅថា ម៉េម៉ូក្រាម (mammogram);
- ✓ ការពិនិត្យមើលឆ្អឹងត្រគាក និងការយកសំណាកកោសិកាពីមាត់ស្បូន (ការបើកមើលស្បូន/កន្ទ្បោមស្បូន) ហៅថា ផែបតេស្ត (Pap test) ។

កម្មវិធី WBCHP អាចនឹងមិនចេញប្រាក់សម្រាប់ថ្លៃធ្វើតេស្តនិមួយៗ ដែលអ្នកផ្តល់ការបម្រើផ្នែកថែទាំសុខភាពរបស់អ្នកបានណែនាំជាអនុសាសន៍ ឲ្យអ្នកទៅធ្វើនោះទេ ។ ចូរឲ្យប្រាកដថា អ្នកបានសាកសួរដល់អ្នកផ្តល់ការបម្រើរបស់អ្នកអំពីអ្វីខ្លះដែល WBCHP ចេញប្រាក់ឲ្យ ហើយអ្វីខ្លះដែលគេមិនចេញប្រាក់ឲ្យ ។ បើ <u>WBCHP មិនចេញថ្លៃ</u>សោហ៊ុយចាយវាយនានានោះទេ, គេអាចនឹងទារប្រាក់ទាំងប៉ុន្មាននេះពីអ្នក ប្រសិនបើអ្នកសម្រេចចិត្តឲ្យគេធ្វើតេស្តបន្ថែមទាំងនេះជូនអ្នកនោះ ។

កម្មវិធីនេះធានាថា អ្នកនឹងបានទទួលលទ្ធផលនៃការធ្វើតេស្តរបស់អ្នក ព្រមទាំងជួយអ្នកឲ្យយល់អំពីលទ្ធផលនៃការធ្វើតេស្តទាំងនោះផង ។ អ្នកក៏នឹងត្រូវគេជួយរំឭកប្រាប់ ឲ្យត្រឡប់មកវិញ ដើម្បីបន្តការពិនិត្យថែទាំ, ការធ្វើផែបតេស្ត, និងការធ្វើម៉េម៉ូក្រាមផងទៀត ។

បើអ្នកមានបញ្ហាសុដន់ ឬស្បូន, អ្នកអាចនឹងត្រូវគេបញ្ជូន ឲ្យទៅជួបជាមួយអ្នកឯកទេសណាម្នាក់ ដែលអាចជួយអ្នកបាន ។ កម្មវិធី WBCHP នឹងចេញប្រាក់សម្រាប់ការធ្វើរោគវិនិច្ឆ័យមួយចំនួនធំ ។ ក្នុងចំណោមដុំសាច់ក្នុងសុដន់ដប់ មានប្រាំបួនត្រូវបានពិនិត្យឃើញថា **មិនមែនជាជម្ងឺមហារីកទេ** ។ ប្រសិនបើអ្នកត្រូវគេធ្វើរោគវិនិច្ឆ័យឃើញថា មានជម្ងឺមហារីកសុដន់ ឬមហារីកស្បូន, អ្នកអាចនឹងមានលក្ខណសម្បត្តិទទួលការព្យាបាលតាមរយៈកម្មវិធីជំនួយ Medicaid របស់រដ្ឋ ។ ក្រោយពេលអ្នកបានប្រគល់សេចក្តីយល់ព្រមអនុញ្ញាតឲ្យគេព្យាបាលរួចហើយ, ពេលនោះ នាយកគ្រប់គ្រងសំណុំរឿងនៃកម្មវិធី WBCHP នឹងជួយចុះឈ្មោះអ្នកក្នុងកម្មវិធី Medicaid ។